**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ ០៩៧.ស.ជ.ណ

ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់អំបិលសមុទ្រសម្រាប់ផលិតក្លរ័ទឹក

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា៖ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងដាក់ឲ្យដេញថ្លៃជាសាធារណៈ ដើម្បីផ្គត់ផ្គង់អំបិលសមុទ្រសម្រាប់ផលិតក្លរ័ទឹក។

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ (៨ព្រឹកដល់១៦:៣០ល្ងាច) ដល់ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨ ត្រឹមវេលាម៉ោង ១៤:៣០រសៀល ក្នុងមួយច្បាប់តម្លៃ ២០០,០០០រៀល។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃគឺ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ១៤:៣០នាទី។

កាលបរិច្ឆេទបើកសំណើដេញថ្លៃគឺ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៨ វេលាម៉ោង ១៤:៣០នាទី នៅអង្គភាពលទ្ធកម្មនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធានទី១**

**បណ្ឌិត ជា វិសុទ្ធ**

ចម្លងជូន៖
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
  "ដើម្បីជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ